# ជូន

ពេលដែលខ្ញុំចាប់ផ្ដើមរៀបរៀងអត្ថបទ «...រស់ព្រោះហ៊ានស្លាប់នេះ» ខ្ញុំសូមលើកដៃទាំងទ្វេផាក់លើសិរសា ឧទ្ទិសផលវិញ្ញាណក្ខន្ធ ៖

* អ្នកម្ដាយដែល ដែលមិនព្រមបញ្ចេញក្ដីខ្វល់ ដែលគាត់មានចំពោះខ្ញុំ ពេលដែលគាត់បានដឹងថា ខ្ញុំទទួលភារៈដឹកនាំការតស៊ូដើម្បីកម្ពុជាក្រោម ។
* លោកតា ថាច់ ហ៊ុយ អាយុ ៥០ ឆ្នាយឆ្នាំ ដែលបានលះបង់ធនៈគាត់ផ្ទាល់មកជួយ យករូបព្រះពុទ្ធជាមួយផង ។
* លោក ឡាំ ណុប អាយុ ៨០ ឆ្នាំឆ្ងាយ ដែលបានលើកទង់ជាតិខ្មែរជាដំបូងបំផុតលើមុខទឹក ផ្គោះទាវកន្ទាំង ។

# ជីវប្រវត្តិ [illegible]



[illegible]
កាលពី ឆ្នាំ ១៩៣៤

*** ខ្ញុំ ម៉ៃ ខាត់ នាមដើម ម៉ៃ ជាត់ ។ សរសេរដោយអក្សរឡាតាំង Mai Khach ត្រូវអានជា ម៉ៃ ខាច់ ដូច្នេះគ្រួសារខ្ញុំ ស្គាល់ខ្ញុំជា ជាត់ យួនហៅខ្ញុំតាមអក្សរគេជា ខាត់ ចិនហៅខ្ញុំ ម៉ួយ ខិ បារាំងហៅខ្ញុំ កាត្យ ។ «កីឡាចំបាប់ម៉្យាង» ។ អ្នកផ្ដការអានឈ្មោះខ្ញុំ ខាច់ ។ នៅឯស្រុកកំណើតកម្ពុជាក្រោម គេស្គាល់ខ្ញុំជា *ថី សោយ សាត់* ។ លុះចូលមកបម្រើក្រសួងអភិវឌ្ឍន៍សហគមន៍ ខ្ញុំបានទទួលឈ្មោះមួយទៀតប្រកបដោយប្រិយភាព គឺលោកតា ខាត់ ។

រីឯខ្លួនឯងវិញ ខ្ញុំប្រាប់គេ-ឯងថាខ្ញុំឈ្មោះ ខាត់ ពីព្រោះមិនចង់ឱ្យគេហៅឈ្មោះខ្ញុំតាមសំបុត្រកំណើត ដែលសរសេរឈ្មោះខ្ញុំខុស ជាត់ ជា ខាត់ មិន ខាត់ ជា ខាច់ នោះទេ ។

កុមារ ខាត់ កើតនៅថ្ងៃ ២៣-១១-១៩១១ ខុសត្រូវគ្នាពីរឆ្នាំពីសំបុត្រកំណើត ដែលចុះខុសទៅជាថ្ងៃ ២៣-១១-១៩១៣ ។ ដូច្នេះ បើគិតមកដល់ថ្ងៃសរសេរអត្ថបទ នេះ

ខ្ញុំត្រូវមានអាយុ ៦០ ឆ្នាំ ២ ខែ ២៨ ថ្ងៃហើយ មិនមែន ៥៨ ឆ្នាំទេ ។ ខ្ញុំកើតនៅភូមិផ្ទោកំបុត សង្កាត់ព្រែកគយ ស្រុកអណ្ដូងទឹក ខេត្តឃ្លាំង ។

គ្រួសារខ្ញុំ ជាកសិករមានអំបូរជាខ្មែរអ្នកជា ជាអ្នកមានធនធានមធ្យម ។ គ្រួសារខ្ញុំជាគ្រួសារស្លូតបូត ប្រកបដោយសប្បុរសធម៌ខ្ពង់ខ្ពស់ណាស់ ។ បានកសាងព្រះវិហារ កុដិ សាលា ក្នុងវត្តពោធិព្រឹក្ស និងស្ពានក្បែរវត្តនោះនៅគង់វង្សរហូតសព្វថ្ងៃ ។ បានបំណាយដីស្រែផ្ទាល់ខ្លួនមួយចំនួន សម្រាប់ធ្វើជាទ្រព្យគរុភ័ណ្ឌ និងជូនដីភូមិបណ្ដោយមួយពាន់ម៉ែត្រផ្លាយ សម្រាប់អ្នកទីទ័លក្រសង់ផ្ទះនៅរហូតសព្វថ្ងៃដោយឥតយកឈ្នួល ។

ជីដូន-ជីតា-ឪពុក-ម្ដាយខ្ញុំ គាត់មិនស្អប់ទេអ្នកមាន តែច្រើនរាប់រកអ្នកក្រជាង ហើយស្រឡាញ់អ្នកវេទនា ។ ប្រហែលជាដោយសារហេតុផលក្រោយនេះហើយ បានជាលោកបំណាយធនធានឲ្យខ្ញុំមក «ស៊ីរៀន» នៅភ្នំពេញចាប់តាំងពីថ្ងៃ១៣ មេសា ១៩២០ «ខ្ញុំអាយុ៩ឆ្នាំ» ។

អស់ពួកណាស់ ខ្ញុំរៀនស្រះអ ស្រះអា នៅស្រុកកំណើតរៀនអា បេ នៅភ្នំពេញ ទៅប្រឡងចូលកូលេសនៅស្រុកយួន ។ មកដល់ត្រឹមនេះ ខ្ញុំមានជំនឿថា អស់លោកអ្នកអានអាចសន្និដ្ឋានបានថា ខ្ញុំមានការវេទនាដឹងផល់ណា ។

ខ្ញុំខ្លួចចិត្តណាស់ ដោយបំពេញបំណាច់ជូនមាតា-បិតា មិនបានដូចចំណង់របស់លោក ប៉ុន្តែលោកមានធម៌មេត្តា ចំពោះខ្ញុំជានិច្ច ព្រោះលោកជាមនុស្សជឿធម៌ ជឿអាថ៌ ដោយលោកបានបញ្ជាក់មកខ្ញុំវិញថា « ឯង គ្មានធម៌បុណ្យដូចគេ » ។

ក្នុងឆ្នាំ ១៩៣៦ ក្នុងកាលខ្ញុំជាមនុស្សម្នាក់មានព្រលឹងតែទៅលើការកសាងកុសល ក៏ក្លាយទៅជាយុទ្ធជនស្ម័គ្រចិត្តម្នាក់ ទទួលបៀវត្សប្រចាំខែ ៣រៀល ៤កាក់កន្លះ ។ នេះជាផលវិបាក គ្រួសារមួយដែល[illegible]មនុស្សចិត្តធម៌ ទៅជាមនុស្សរៀនកាប់ចាក់បាន ។

ចាប់តាំងពីឆ្នាំ១៩៣៦ មក ខ្ញុំដែលធ្លាប់តែធ្វើអំពើល្អ ធ្លាប់តែឮពាក្យទូន្មានឱ្យដើរ ផ្លូវត្រង់ ផ្លូវត្រូវ ដូចយ៉ាងដូចជាលោកតាខ្វូត នឹង ខ្ញុំ ដែលអ្នកផងទទួលស្គាល់ថាគាត់មានលក្ខណៈជាអ្នកដឹកនាំ ហើយមាននាទីជា ឧត្តមប្រឹក្សារបស់រដ្ឋការខេត្តឃុំខណ្ឌ គាត់តែងទូន្មានខ្ញុំថា៖ កើតមកជាមនុស្ស បើមិនបានធ្វើល្អ ក៏កុំតែប្រព្រឹត្តអាក្រក់-បើមិនបានធ្វើបុណ្យ ក៏កុំតែសាងបាប ធ្វើឱ្យគេទឹកភ្នែក ជៀសវាងមិនរួចតែពេលមានសង្គ្រាមឯណោះសោះ ក៏ខ្លួនខ្ញុំក្លាយទៅជាអ្នករៀនតែបាញ់ ប្រយុទ្ធ ដោយកាំបិត-ចំពុះទុង-រៀនតែបង្កើតទោស ទាំងសម្លាប់សត្រូវ ។

ក្រោយពីបានចូលរៀនក្នុង សាលា យោធាខាខា នៅក្រុងព្រៃនគរ នៅខួលតាមោគនៅអ្នកាប់មក ខ្ញុំបានទទួលសញ្ញាប័ត្រ ប្រើវើដឺសេហ្វឺសិចស៊ីយ៉ុង ក្នុងឆ្នាំ ១៩៣៧ដែលមានពិន្ទុរហូតដល់ទៅ ១៨,៣៦ ក្រោយមកបានបំពេញវិជ្ជាផ្នែកវិជ្ជាយុទ្ធសាស្ត្រអនុវត្តិប្រឡងចេញជាប់លេខ ១ ឆ្នាំ ១៩៤១ ខ្ញុំធ្វើជាគ្រូបង្ហាត់វិជ្ជាយុទ្ធសាស្ត្រនៅខួលតាមោគ «កម្ពុជាក្រោម» ។ ក្រោយមក ខ្ញុំបានច្បាំងនឹងសៀម និងជប៉ុន និងវៀតមិញ ។ ឧត្តមសេនិយក៏ហារឈ្មោះ ត្រឹង យ៉ុង ស្វាយ ហៅ ណាំលៀ បានឲ្យគេតាមសម្លាប់ខ្ញុំ ។ ខ្ញុំក្រឡាប់ឡាន ៣ ដង បាក់ស្មារទាំងពីរ ។ ខ្ញុំត្រូវរបួសពេលប្រយុទ្ធនៅហាទៀង ។

នៅយប់ ៩ មីនា ១៩៤៥ ខ្ញុំត្រូវជប៉ុនចាក់នឹងចំពុះទុងតាមប្រហោងទ្វារដែក ប៉ុន្តែជាសំណាងល្អ ខ្ញុំគេចផុត ។

ព្រលឹមថ្ងៃ ១០ មីនា ១៩៤៥ ខ្ញុំប្ដូរស្លាប់ដើម្បីយកទៅហ្វាយចាស់ដែលបរាជ័យ ទៅលាក់នៅភូមិចាម ហៅភូមិ ប៉ូវយ៉ាង. ក្នុងស្រុកមាត់ជ្រូក ។ រសៀលថ្ងៃ ១០ មីនា ១៩៤៥ ខ្ញុំត្រូវជាប់គុកជប៉ុន ។ ពេលយប់ខ្ញុំគេចរត់រួចទៅលាក់ខ្លួនក្នុងទ្រុងពពែនៅផ្ទះយួន ដែលខ្ញុំស្គាល់នៅជិតផ្សារទាំងលើ ។ ព្រឹកឡើងយកអីក៏ង់បន្តិចបន្តួចចំព្រួសារ និង ភូនភួចៗ ធ្វើងូកទៅនៅផ្ទះចាម នៅភូមិ

ស្វាយ ត្រូវចោរលួចអស់ខ្លះ ។

ថ្ងៃ ២០ មីនា ១៩៤៥ យួនដែលខ្ញុំជួលថែរក្សានោះទៅស្រុកកំណើត ប្រាថ្នាចង់សម្លាប់ខ្ញុំដើម្បីយកអីវ៉ាន់ខ្លះទៀត ប៉ុន្តែសំណាង បានមិត្តភក្តិដែលទៅជាមួយដឹងទាន់ ។

បារាំងចាញ់ជប៉ុន ខ្ញុំត្រូវអស់លក្ខណ៍ទៅសម្ងំធ្វើស្ងួតក្នុងផ្ទះឪពុក-ម្តាយនៅកម្ពុជាក្រោម ។ ខ្ញុំរៀនត្បាញ ចេះរវៃ ចេះទារ ឱ្យបាយអំបោះ ចេះអន្លូង ។ល។

យួនតែកនោផ្ទះខ្ញុំរកការកើត យួនយកខ្ញុំធ្វើជាសត្រូវ ម៉្លោះហើយ ខ្ញុំនិងភរិយាខ្ញុំ ដោយញាតិមិត្តជួយផង ទំរស់នៅជាមួយញាតិ មិត្ត ហើយទទួលយកស្រែពីម្តាយ-ឪពុកខ្ញុំធ្វើបានជាង ១.០០០ថាំងបាយក្នុងឆ្នាំនោះ ។

ថ្ងៃ ២ មករា ១៩៤៦ ខ្ញុំត្រូវបង្ខំចិត្តដឹកនាំចលនាគស៊ីនៅកម្ពុជាក្រោម ដែលអ្នកម្ចាស់មានអំណាច មានមហិទ្ធិឫទ្ធិ អ្នកម្ចាស់ទៀត គ្មានអ្វីមានក្រៅពីខ្ទះចង់រស់ជាមនុស្សមានសេរីភាពក្រោមគន្លងយុត្តិធម៌ ។ ជាការប្រយុទ្ធមួយដ៏ទ្វី ប៉ុន្តែសាហាវ ក្រៃណាសាហាវ ដូចខ្ញុំនិងរៀបរាប់ជូនក្នុងទំព័រខាងក្រោមនេះ ។

ពីរខែក្រោយមក ពេលបារាំងត្រឡប់មកវិញ ស្រួលបួលហើយ គេឱ្យខ្ញុំធ្វើអភិបាលស្រុក ។ ក្នុងមុខងារថ្មីនេះ ខ្ញុំបានធ្វើការកសាងសន្តិភាព រហូតដល់គួសត្រូវ

និយាយស្តាប់គ្នាបានដូចដើមវិញ ហើយបានរក្សាសន្តិភាពរាប់រកគ្នារហូតសព្វថ្ងៃ ។

លុះឆ្នាំ ១៩៤៦ ខ្ញុំបានទទួលបានងារសក្តិជា ព្រឹទ្ធបាលទោ ហើយទទួលបញ្ជាឲ្យចូលបម្រើកងទ័ពសម្ព័ន្ធមិត្តនៅក្នុងកងពលលេខ ៤៣ ដែលមានសកម្មភាពនៅក្នុងខេត្តទឹកខ្មៅ ក្នុងមុខងារជាមេបញ្ជាការកងអនុសេនាតូច ដែលមាននាយទាហានរង និងពលទាហានជាជាតិបារាំងសុទ្ធ ។

ឆ្នាំ ១៩៤៧ ខ្ញុំត្រូវផ្លាស់មកមាត់ជ្រូក ក្រោយមក មកនៅតាកែវ និងកំពត មានបានងារសក្តិជាព្រឹទ្ធបាលឯក បំពេញមុខងារជានាយទាហានខាងបរិក្ខារក្នុង កងវរសេនាតូចនៃកងទ័ពជាតិ ដែលមានវរសេនិយទោ តូម៉ា ជាមេបញ្ជាការ ។

ឆ្នាំ១៩៤៩ ខ្ញុំចូលមកធ្វើជានាយករងនៃការិយាល័យពត៌មាន នៅវរសេនាធិការដ្ឋាននៃកងទ័ពសម្ព័ន្ធមិត្តនៅក្រុងភ្នំពេញ ។

ចាប់តាំងពីថ្ងៃ ២៩-១១-១៩៥០ ខ្ញុំធ្វើជាអភិបាលស្រុករមាស-កំពង់លែង ខេត្តកំពង់ឆ្នាំង ស្វាយទៀប-ស្វាយរៀង ខេត្តស្វាយរៀង បន្ទាយមាស-កំពត ខេត្តកំពត និងនៅសួង ខេត្តកំពង់ចាម រហូតដល់ឆ្នាំ ១៩៦៨ ដែលជាថ្ងៃចូលនិវត្តន៍ ។ ក្នុងមុខងារថ្មីដែលខ្ញុំបំរើអស់ ១៨ ឆ្នាំ ខ្ញុំ

បាទក៏ក្លាយទៅជាមន្ត្រីរដ្ឋបាលមួយរូប ដែលខិតខំធ្វើការ ហើយប្រមែប្រមូលបងប្អូនយើង ដែលវង្វេងចូលមករកសង្គមជាតិវិញចំនួន ជាង៥០០ នាក់ ៗ ខ្ញុំបានយកចិត្តទុកដាក់ជាពិសេសទៅលើការប្រយុទ្ធជាមួយទ័ពឈ្លានពាន និងរួមដំណើរជាមួយសង្គមខ្មែរគ្រោះទៅរកឡេនភាព តាមកម្លាំងដែលខ្ញុំធ្វើទៅបាន មានជួយរំដោះបងប្អូនខ្មែរលើឲ្យរួចផុតពីកណ្ដាប់ដៃខ្មាំង នៅឃុំក្បាលទឹក - តាំងជ្រាច - តាប្រង់ ច្រើនពាន់គ្រួសារក្នុងខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៥៦ ជាដើម ៗ ក្នុងឆ្នាំ ១៩៥៩ ធ្វើជាភូឈួយខេត្តទី ១ នៃខេត្តស្វាយរៀង ៗ ក្នុងការបំពេញបែបនេះ ខ្ញុំបានទទួលឥស្សរិយយសការពារជាតិចំនួន ៣ រាប់ទាំងរបស់សាធារណរដ្ឋបារាំងមួយ គ្រឿងផង មេដាយមាស ៣ មេដាយប្រាក់និងសំរិទ្ធ ១០ គ្រឿងទៀត ៗលៗ

ក្រោយ ១៨ មីនា ១៩៧០ គឺនៅថ្ងៃ១ ខែសីហា១៩៧០ ខ្ញុំបានទទួលឋានន្តរសក្តិជា អនុសេនីយឯក ហើយបានមកបំរើក្រសួងអភិវឌ្ឍន៍សហគមន៍រហូតសព្វថ្ងៃ ក្រោយពីបានចូលបំពេញវិជ្ជានៅបណ្ឌិតសភាយោធានៅក្រុងភ្នំពេញ ៗ